**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:.....០១.....បប...**

# បទបញ្ជា

## ស្ដីពី

## ការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ

*****

ព្រៃឈើគឺជាសម្បត្តិធម្មជាតិដែលមានតម្លៃមិនអាចកាត់ថ្លៃបានចំពោះមនុស្សជាតិ និងសត្វនៅលើផែនដី ។ ដោយមើលឃើញនូវសារៈសំខាន់របស់ព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព សំដៅបំរើឱ្យផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថានសំរាប់មនុស្សជំនាន់បច្ចុប្បន្ន ក៏ដូចជាសំរាប់អនាគតផងដែរ ។

ផ្ដើមចេញពីទស្សនៈវិស័យខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទបញ្ជាលេខ ០២ ចុះថ្ងៃទី៦-០១-១៩៩៩ សេចក្ដីប្រកាសលេខ ០១ ចុះថ្ងៃទី ២៥-០១-១៩៩៩ និងសេចក្ដីប្រកាសលេខ ០៦ ចុះថ្ងៃទី ២៧-៩-១៩៩៩ ដើម្បីគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ និងការទន្រ្ទានកាន់កាប់ដីធ្លី និងបានអនុវត្តកំណែទម្រង់វិស័យព្រៃឈើដ៏ស៊ីជំរៅមួយប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យជាបន្តបន្ទាប់ ព្រមទាំងទទួលបាននូវការវាយតម្លៃខ្ពស់ និងការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់មតិជាតិ និងអន្តរជាតិ ។ ប៉ុន្តែទន្ទឹមនឹងនេះ សកម្មភាពកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ចំការព្រៃដាំ និងតំបន់ការពារធម្មជាតិធ្វើជាកម្មសិទ្ធិដែលធ្លាប់កើតមានឡើងកន្លងមកនេះ កាន់តែមានសភាពកើនឡើងជាបន្តបន្ទាប់ស្ទើរនៅគ្រប់ខេត្ត ក្រុង ។ ទង្វើនេះជាឧក្រិដ្ឋកម្មបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្ដីពីព្រៃឈើ និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត ដែលជាសកម្មភាពអាចនាំទៅរកគ្រោះមហន្តរាយ វិនាសកម្មព្រៃឈើ និងបាត់បង់សម្បត្តិព្រៃឈើរបស់រដ្ឋ ព្រមទាំងអាចធ្វើឱ្យបរាជ័យនូវគោលដៅគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ប្រសិនបើវិធានការទប់ស្កាត់ និងបង្ក្រាបពុំត្រូវបានអនុវត្តឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពបានទាន់ពេលវេលានោះទេ ។

ចំពោះមុខ ដើម្បីទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ រាជរដ្ឋាភិបាលបាន សំរេចដាក់ចេញនូវបទបញ្ជាបន្ទាន់ដូចខាងក្រោម :

១- លុបចោលរាល់លិខិតកាន់កាប់ដីធ្លី និងប័ណ្ណសំគាល់សិទ្ធិដីទាំងឡាយណាដែលបានមកពីការកាប់រានដីព្រៃឈើ ចំការព្រៃដាំកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន ស្របតាមច្បាប់ស្តីពីព្រៃឈើ និងច្បាប់ភូមិបាល ។ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវធ្វើការណែនាំដល់អង្គភាពក្រោម ឱវាទឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការចេញលិខិតកាន់កាប់ ឬប័ណ្ណសំគាល់សិទ្ធិដីធ្លី ដែលមានប្រភពពីការកាប់រានដីព្រៃឈើ និងព្រៃដាំរបស់រដ្ឋ ។ រាល់ការចេញលិខិត ឬប័ណ្ណសំគាល់សិទ្ធិដីធ្លី ដែលពាក់ព័ន្ធនឹងដែនព្រៃឈើ ត្រូវមានមតិឯកភាពពីសមត្ថកិច្ចរដ្ឋបាលព្រៃឈើនៅមូលដ្ឋាននោះ ។

២- ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវរៀបចំគំរោងផែនការបោះទីតាំងមូលដ្ឋានទ័ពឱ្យមានលក្ខណៈអចិន្ត្រៃយ៍ ដោយជៀសវាងការប៉ះពាល់តំបន់ព្រៃឈើ ។ ក្នុងករណីមានការប៉ះពាល់ដល់ដែនព្រៃឈើ ត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមុន ។

៣- ហាមដាច់ខាតការបោះដាក់តាំងលំនៅដ្ឋានថ្មីតាមផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ មុនពេលមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវគ្រប់គ្រងឱ្យបានល្អនូវស្ថិតិប្រជាជនមូលដ្ឋាន និងត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលាចំពោះប្រជាជនត្រាច់ចរ ដែលដើរកាប់រាន ដុត ឈូសឆាយ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ និងសង់លំនៅដ្ឋានក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ក្រោមរូបភាពធ្វើចំការពនេចរ ឬក្រោមគោលបំណងផ្សេងទៀត ។

៤- ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសំរេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ដោយត្រូវមានការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៥- ការអនុវត្តចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃស្រោង និងពាក់កណ្តាលស្រោង ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ ចំការពនេចរអាចអនុវត្តបានចំពោះតែប្រជាជនសហគមន៍ជនជាតិដើមភាគតិចតែប៉ុណ្ណោះ ដោយត្រូវមានការពិនិត្យ និងយល់ព្រមពីសមត្ថកិច្ចជំនាញនៅមូលដ្ឋាន ។

៦- ការជីកយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

៧- គ្មានរូបវន្តបុគ្គល នីតិបុគ្គល សមាគម អង្គការ ឬអាជ្ញាធរណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំការព្រៃដាំរបស់រដ្ឋជាដាច់ខាត ។

៨- ដីព្រៃឈើទាំងអស់ដែលបានដកហូតយកមកវិញស្របតាមច្បាប់ស្តីពីព្រៃឈើត្រូវទុកជាសម្បត្តិរដ្ឋ ហើយរដ្ឋបាលព្រៃឈើ ត្រូវធ្វើការដាំដុះដើមឈើ ដើម្បីបង្កើតជាព្រៃឈើឡើងវិញជាចាំបាច់ ។

៩- ការនាំចូលរណារយន្តកាត់ឈើ (Chainsaw=Tronçonneuse) គ្រប់ប្រភេទ អាចប្រព្រឹត្តទៅបានតែតាមរយៈរដ្ឋបាលព្រៃឈើប៉ុណ្ណោះ ។ រដ្ឋបាលព្រៃឈើត្រូវធ្វើការចាប់ឃាត់ និងប្រមូលទុកនូវរាល់រណារយន្តកាត់ឈើ (Chainsaw=Tronçonneuse)

គ្រប់ប្រភេទដែលគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដែលបានជួបប្រទះឃើញ ។ រណារយន្តទាំងអស់ដែលប្រមូលបានត្រូវរៀបចំធ្វើពិធីកំទេចចោលដូចករណីកំទេចឧបករណ៍នេសាទខុសច្បាប់ដែរ ។

១០- រាល់ការចេញលិខិត ឬប័ណ្ណសំគាល់សិទ្ធិដីធ្លី ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ការបោះទីតាំងមូលដ្ឋានទ័ព ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ការតាំងលំនៅដ្ឋានថ្មីតាមផ្លូវសាធារណៈ ការធ្វើចំការពនេចរ ការជីកយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិ ដែលពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងបរិស្ថាន ជាមុន ។

១១- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ កងរាជអាវុធហត្ថ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និងផ្តល់កម្លាំងចូលរួមសហការជាមួយសមត្ថកិច្ចរដ្ឋបាលព្រៃឈើមូលដ្ឋាន តាមការស្នើសុំ ដើម្បីចាត់វិធានការទប់ស្កាត់ និងបង្ក្រាបការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទ។

១២- ជនណាដែលមិនបានអនុវត្តតាមបទបញ្ជានេះ ត្រូវទទួលទោសទណ្ឌដូចមានចែងកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ជាធរមានផ្សេងៗទៀត ។

ទទួលបានបទបញ្ជានេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តបទបញ្ជាខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន